

ពេលយប់អាធ្រាត្រ ចិន្តាបានបង្ហាញរបស់មួយដល់ធីតា ។
វាគឺជាកន្ត្រងសម្រាប់បក់ចាប់សត្វល្អិត ។



"ខ្ញុំយករបស់នេះមកសម្រាប់ឯង ធីតា ។ ខ្ញុំដឹងថាឯង
ចង់ដឹងតើពួកស្រឹងណាដែលស៊ីបំផ្លាញផ្លែសណ្តែក
សៀង ។ ប្រហែលជាឯងអាចចាប់ពួកវាបានដោយ
ប្រើកន្ត្រងនេះ" - ចិន្តានិយាយ ។





ក្រោយពីធីតាភ្ញាក់ពីដំណេក នាងប្រញាប់ប្រញាល់ចាប់យកកន្ទ្រងចាប់សត្វល្អិត ហើយដើរតម្រង់ទៅចំការដំណាំរបស់នាង ។ នាងដើរទៅ ដើរមកតាមចន្លោះរងដំណាំ ហើយគ្រវីកន្ទ្រងចាប់សត្វល្អិតពីម្ខាងទៅម្ខាង ។ វាជាការងារមួយដែលពិបាក ។ ធីតាមានការនឿយហត់ និងក្តៅយ៉ាងខ្លាំង ។





នៅពេលដែលនាងបានមកដល់ផ្ទះ នាងបានមើលនូវអ្វីដែលនាងចាប់បាន ។ មានស្រីងចម្លែកខ្លះរស់នៅក្នុងចំការទាំងនោះ- ស្រីងដែលនាងមិនដែលបានឃើញពីមុនមក ។ មានស្រីងខ្លះរាងដូចស្រមោច និងខ្លះទៀតរាងដូចរុយ ។ មានស្រីងដទៃទៀតមានរូបរាងដូចពួកសត្វល្អិតស្លាបរឹង ( ខ្ទូត ) និងមានសត្វល្អិតតូចៗជាច្រើនទៀតដែលនាងចាប់បាន ។



" តើអាមួយណា ដែលឯងគិតថាពួកវាស៊ីបំផ្លាញផ្លែសណ្តែក? -ម្តាយនាងបានសួរ" ។

ធីតាឆ្លើយ- "ខ្ញុំមិនប្រាកដទេ" ។ ល្ហើយ! យើងគួរតែប្រើកន្ទ្រងនេះបក់ចាប់ម្តងទៀត នៅពីរសប្តាហ៍ក្រោយ ។ នៅពេលនោះផ្លែសណ្តែកនឹងធំជាងនេះ ។



វាជាការទន្ទឹងរង់ចាំមួយយ៉ាងយូរ ។ ធីតាបានចំណាយពេលជារៀងរាល់ថ្ងៃ ដើម្បីពិនិត្យមើលពួកស្រឹង ។ នាព្រឹកមួយ នៅពេលដែលនាងអង្គុយ



យ៉ាងស្ងៀមស្ងាត់ក្នុងចំការដំណាំ នាងបានឃើញស្រឹងមួយប្រភេទស៊ីស្រឹងមួយផ្សេងទៀតនៅចំពីមុខរបស់នាង! នាងមានអារម្មណ៍ក្រៀមក្រំចំពោះស្រឹងនោះដែលក្លាយជាអាហារថ្ងៃត្រង់របស់គេ ប៉ុន្តែនាងយល់ថា វាជាសត្វដែលរុំតោងផ្លែសណ្តែកសៀង ។ *តើវាប្រហែលជាអាមួយដែលទើបតែជញ្ជក់រុក្ខរសពីផ្លែសណ្តែកសៀងឬ?*-នាងឆ្ងល់ ។

នាងបានសម្លឹងមើលជុំវិញ នាងច្បាស់ក្នុងចិត្តថា ប្រាកដជាវាហើយ ។ ចំនួនច្រើននៃស្រឹងទាំងនោះកំពុងតែចោមរោមនៅលើផ្លែសណ្តែក ។

"ហេតុដូច្នេះហើយ ពួកឯងជាអ្នកទោស"- ធីតាបាននិយាយខ្សឹបៗ ។

នាងបានយករឿងនេះទៅប្រាប់ម្តាយនាងយ៉ាងរួសរាន់ ។



"ម៉ែ! ខ្ញុំដឹងអ្វីដែលបានស៊ីបំផ្លាញផ្លែសណ្តែកហើយ! មើលនែ! ធីតាបាន ស្រែកហៅនៅខណៈពេលដែលនាងច្រានបើកទ្វា ហើយទន្ទឹមនឹងនោះ នាងក៏បានលើកចង្កោមផ្លែសណ្តែកដែលមានផ្លែថ្លោសៗឡើងដែរ ។

ចិន្តាបានក្រោកឈរឡើងដើម្បីពិនិត្យអោយបានកាន់តែច្បាស់ ។ នាងបាន ពិនិត្យមើលយ៉ាងជិត ហើយនាងបានឃើញមានពួកស្រឹងតូចៗមួយកញ្ចុំ កំពុងវារនៅលើផ្លែសណ្តែកដែលស្ថិតនៅក្នុងដៃរបស់ធីតា ។

ពួកស្រឹងទាំងនេះហើយដែលរោមតោងលើផ្លែសណ្តែកនាពេលនេះ ។ ពួកវានេះប្រាកដជាពពួកស៊ីបំផ្លាញដំណាំ!" ។

"ធ្វើបានល្អណាស់ កូនស្រីឆ្លាត"-ចិន្តានិយាយ ។ "ឥឡូវនេះយើងដឹង សត្វណាជាសត្វអាក្រក់ (សត្វចង្រៃ) ហើយ" ។







"ខ្ញុំបានឃើញស្រឹងធំមួយខាំស៊ីពួកស្រឹង នេះនៅពេលដែលវាតោងលើផ្លែ សណ្តែក និងមានស្រឹងជាច្រើនផ្សេង ទៀត ហើយខ្ញុំគិតថាពួកស្រឹងដែលមាន មាឌធំៗ ស៊ីពួកទាំងនេះ!"- ធីតា និយាយយ៉ាងលឿនដោយរួមជាមួយ នឹងសេចក្តីរំភើបរីករាយ ។

"កូននិយាយដូច្នេះត្រឹមត្រូវហើយ ធីតា ។ ពួកស្រឹងធំៗទាំងនេះគឺជាអ្នក ជួយយើង ។ ការបាញ់ថ្នាំរបស់យើង បានសម្លាប់ពួកស្រឹងមានប្រយោជន៍ ទាំងនេះដែរ ។

ធីតា និងចិន្តាគឺជាអ្នកស្វែងយល់អំពីការរកឃើញរបស់ពួកគេ ។ ពួកគេបានឮអំពីសាលារៀនស្រែកសិករមួយដែលកំពុងតែបើកបង្រៀននៅសំឡូតដូច្នេះហើយពួកគេបានសម្រេចចិត្តទៅចូលរួមក្នុងវគ្គនោះ ដើម្បីទទួលបាននូវចំណេះដឹងច្រើនបន្ថែមទៀត ។

ពួកគេគ្រាន់តែមន្ទិលសង្ស័យនៅពេលនោះ ។ ពួកគេត្រូវបានប្រាប់ថាពួកស្រីងតូចៗដែលធីតាបានរកឃើញគឺជញ្ជក់រុក្ខរសពីផ្លែសណ្តែក ។





ពួកវាក៏មានសត្រូវរបស់វាដែរ ។ សត្រូវរបស់វាគឺពពួកប៉ារ៉ាស៊ីត ដែលធ្វើអោយមានគ្រោះថ្នាក់ ឬសម្លាប់ពួកស្រីងបៃតង និងពួកសត្វរំពារ ( ប្រេដាទ័រ) ដែលចាប់ស៊ីពពួកស្រីងបៃតងនេះ ។

កសិករត្រូវការពិនិត្យសត្វល្អិតអ្វីខ្លះដែលកំពុងរស់នៅក្នុងដំណាំ មុនពេលធ្វើការសម្រេចចិត្តបាញ់ថ្នាំ ពីព្រោះពួកគេ ( កសិករ) អាចនឹងសម្លាប់ពួកប្រេដាទ័រ និងប៉ារ៉ាស៊ីតទាំងនេះជាមួយនឹងពួកស្រីងបៃតង ។

ប្រសិនបើបញ្ហានេះកើតមានឡើង ពួកស្រីងចង្រៃខ្លះដែលរត់គេចផុតពីការបាញ់ថ្នាំអាចវិលត្រឡប់មកស៊ីបំផ្លាញដំណាំវិញ និងបង្កើនចំនួនវាកាន់តែច្រើនក្នុងរយៈពេលដ៏ខ្លី នៅពេលដែលអស់ជាតិថ្នាំ ពីព្រោះគ្មានពួកប្រេដាទ័រ និងប៉ារ៉ាស៊ីតនៅរំខានដល់ពួកវាទៀតឡើយ ។

ធីតា និងចិន្តាបានធ្វើការងារនៅក្នុងចំការរបស់ពួកគេជាទៀងទាត់ដូចជាជំរះស្មៅ និងពិនិត្យមើលពួកសត្វល្អិតអ្វីខ្លះដែលកំពុងរស់នៅក្នុងចំការដំណាំ ។ ផ្លែណ្ដែកសៀងរបស់ពួកគេលូតលាស់ធំធាត់ និងគ្រាប់ខាងក្នុងរាងមូលរលោង ថ្លោស និងមានពណ៌ពោរពេញទៅដោយប្រេង ។ នេះវានឹងក្លាយជាការប្រមូលផលយ៉ាងល្អប្រសើរបំផុតរបស់ពួកគេ ដែលមិនធ្លាប់មានពីមុនមក ។





*បន្ទាប់ពីពេលនោះមក ចំការដំណាំរបស់យើងកំពុងត្រូវបានថែទាំយ៉ាងល្អ -* ធីតាគិត ។

នៅទីបំផុត ដំណាំសណ្ដែកសៀងដល់ពេលទុំ ។ ចិន្ដាបាន អញ្ជើញមិត្តភ័ក្ដិ និងក្រុមគ្រួសារមកជួយប្រមូលផល ដំណាំរបស់នាង ។

នាថ្ងៃប្រមូលផល គ្រប់គ្នាបានភ្ញាក់ពីព្រលឹម និងមាន ទឹកមុខស្រស់ថ្លា មានសំណើចលាយឡំនឹងការនិយាយ កំប្លែងលេងយ៉ាងសប្បាយ ។ វាជាថ្ងៃសប្បាយរីករាយ មួយ ។



ប្រជាពលរដ្ឋមានការភ្ញាក់ផ្អើល និងងឿងឆ្ងល់ទៅ លើផលដំណាំដ៏ច្រើនសន្ធឹកសន្ធាប់នេះ ។ ប៉ុន្ដែ ធីតា និងចិន្ដាបានដឹងពីបញ្ហានេះ ពីព្រោះពួកគេ បានមើលថែទាំដំណាំរបស់ពួកគេយ៉ាងប្រុងប្រយ័ត្ន ដោយទុកអោយស្រឹងមានប្រយោជន៍រស់នៅក្នុង ចំការ និងស៊ីពួកស្រឹងចង្រៃ ។

ក៏ប៉ុន្ដែមិនមែនមនុស្សគ្រប់គ្នាសប្បាយចិត្តឡើយ ។



អ្នកជិតខាងរបស់ធីតាជាច្រើនបានទទួលផល
ដំណាំមិនល្អទេនៅឆ្នាំនោះ ។ ពួកគេមិនយល់
ហេតុអ្វីបានជាដំណាំរបស់ពួកគេមិនបានអោយ
ផលល្អដូចដំណាំរបស់ចិន្តា និងធីតា ។ ធីតាចង់
ជួយអ្នកជិតខាងរបស់នាង ដូច្នេះហើយនាងបាន
សួរទៅម្តាយនាង ថាតើនាងអាចអញ្ជើញពួកគេ
ទាំងនោះមកផ្ទះរបស់នាងបានឬអត់ ។ ពួកគេទាំងអស់
(អ្នកជិតខាង) បានស្តាប់យ៉ាងយកចិត្តទុកដាក់បំផុត
នៅពេលដែលធីតានិយាយប្រាប់ពួកគេ នូវរឿងរ៉ាវដែល
ធ្វើអោយគ្រួសាររបស់នាងទទួលបានផលដំណាំល្អ ។

